

# ដូចគ្នា ឬ ខុសគ្នា

Roopa Pai

Rohit Kelkar

Let's Read

The Asia Foundation



ម៉ែចាបរៀបចំខ្ចប់ប្រអប់អាហារក្នុងកាតាបឱ្យកូនយកទៅសាលារៀន រួចលើកស្លាបឱបកូន ហើយបានផ្ដាំកូនថា «ទៅរៀនឱ្យសប្បាយណាកូន! ត្រូវយកចិត្តទុកដាក់រៀនសូត្រ និងត្រូវចេះគួរសមផង!»។ កូនចាបសើច «ហាសហា... ម៉ែនិយាយដដែលៗរាល់តែថ្ងៃ!»។



ហើយម៉ែចាបនិយាយទៀតថា «ចូរចាំណាកូន! នៅឱ្យឆ្ងាយពីសត្វពស់។ ពស់មិនដូចយើងទេ»។

កូនចាបមិនចង់ឮម៉ែវានិយាយបែបនេះទេ។ ពស់ជាមិត្តល្អបំផុតរបស់វា។ តែម៉ែវាមិនចូលចិត្តសត្វពស់ឡើយ។ ម្ដាយរបស់វាតែងនិយាយថា «ពស់ស៊ីសត្វចាប។ ចាប និងពស់មិនអាចធ្វើជាមិត្តនឹងគ្នាបានទេ»។



នៅផ្នែកម្ខាងទៀតនៃទីក្រុង ឪពស់ក៏កំពុងរៀបចំប្រអប់អាហារ ដែលមានសុទ្ធតែពងចាប។ ឪពស់និយាយដោយមោទនភាពថា «ថ្ងៃនេះ យើងមានម្ហូបពិសេស»។ កូនពស់បានស្រែកតបទាំងមិនសប្បាយចិត្តថា «តែកូនមិនចូលចិត្តញុំាពងចាបទេ!»។



ឪពស់និយាយយ៉ាងម៉ឺងម៉ាត់ថា«អម្បូរពស់របស់យើងតែងតែស៊ីស៊ុតជាអាហារតាំងពីដើមមកហើយ។ ឥឡូវឆាប់ចេញទៅសាលាទៅ ហើយត្រូវចាំថាត្រូវនៅឱ្យឆ្ងាយពីពពួកចាប!»។ ពស់ជាកូនបានវារចេញទាំងកំហឹង។ ឪស្រែកបន្ថែមទៀតថា«ចាបខុសពីយើង។ កូនមិនអាចរាប់អានមិត្តដែលជាចំណីរបស់ខ្លួនបានទេ»។



នៅពេលសត្វពស់បានជួបសត្វចាបនៅសាលា ពួកគេបានដឹងពីរឿងនេះ។ កូនពស់សួរថា «ម៉ែរបស់ឯងនិយាយថា...» កូនចាបបានងក់ក្បាល។ «ឪរបស់ឯងនិយាយដូចគ្នាមែនទេ?» កូនពស់ងក់ក្បាល។ កូនពស់និយាយថា «ម៉ែ និងឪរបស់ពួកយើងគិតខុសហើយ ចាប។ តោះធ្វើឱ្យពួកគាត់ឃើញថា យើងមានលក្ខណៈដូចគ្នាច្រើនជាងលក្ខណៈខុសគ្នា»។



កូនចាបនិយាយថា «គំនិតល្អ តោះយើង!»។ នាងបានទាញក្រដាសមួយសន្លឹកចេញមក ហើយគូររង្វង់ពីរ - ដូចរូបខាងលើ។





កូនចាបនិយាយថា «នៅក្នុងរង្វង់ខាងឆ្វេងពណ៌លឿង យើងសរសេរអ្វីដែលទាក់ទងនឹង សត្វចាប។ នៅក្នុងរង្វង់ខាងស្តាំពណ៌ខៀវ យើងសរសេរអ្វីដែលទាក់ទងនឹង សត្វពស់។ ទាំងនេះគឺជាភាពខុសគ្នារវាងសត្វពស់ និងសត្វចាប»។ ពស់ឆ្ងល់ថា «ខ្ញុំគិតថា ក្រែងយើងស្វែងរកចំណុចដែលយើងមានដូចគ្នាអ្វី!»។ សត្វចាបបានញញឹម រួចនិយាយថា «វាគឺសម្រាប់ផ្នែកកណ្តាល ពណ៌បៃតង»។



កូនចាបនិយាយថា «ដំបូងសាករកនឹកពីរូបរាងរបស់ពួកយើង។ ដូចគ្នា ឬខុសគ្នា?»។ ពស់ដកដង្ហើមរួចឆ្លើយថា «ខុសគ្នាឆ្ងាយណាស់។ ខ្ញុំមានរូបរាងវែង គ្មានរោម ហើយស្គម។ ចំណែកឯងមានមាឌតូចមូល និងមានរោមទន់ល្មើយ»។ កូនចាបនិយាយថា «ឯងនិយាយត្រូវ។ ខ្ញុំមានរោមទន់ដូចសំឡី»។ ចាបក៏គូររូបដុះសំឡីក្នុងរង្វង់ពណ៌លឿង។ រួចនិយាយបន្តថា «ចំណែកឯងមានរាងដូចជាខ្សែពួរ»។ នាងក៏គូររូបខ្សែពួរក្នុងរង្វង់ពណ៌ខៀវ។



កូនចាបនិយាយថា «ពេលនេះ មកមើលពីការធ្វើដំណើរវិញម្តង តើពួកយើងផ្លាស់ទីដោយដូចម្តេច?»។ ពស់បាននិយាយយ៉ាងក្រៀមក្រំថា «ឯងហោះហើរខ្ពស់ ចំណែកខ្ញុំវិញ វារនៅលើដី»។ កូនចាបបានបន្តថា «និយាយទៅខ្ញុំអាចហោះបានដូចជាយន្តហោះ ចំណែកឯងវិញ វារដូចជារថភ្លើង។»



ពស់ដកដង្ហើមធំ។ ចាបនិយាយយ៉ាងលឿនថា «រឹងមាំឡើង ពស់ តោះ ឥឡូវរកមើលថា យើងស៊ីអ្វី?»។ ពស់និយាយទាំងទឹកភ្នែករលីងរលោង «យើងស៊ីអាហារខុសគ្នាខ្លាំងណាស់ តែខ្ញុំមិនបរិភោគពងចាបនោះទេ»។



ចាបបាននិយាយយ៉ាងទន់ភ្លន់ថា «ខ្ញុំដឹង»។ ប៉ុន្តែពេលនេះ វាមើលទៅដូចជា ស្រងូតស្រងាត់ដូចគ្នា។ «គ្រាប់ និងស្មៅ» នាងបាននិយាយស្របពេលនាងបានគូរនៅក្នុងចំណិតរង្វង់ពណ៌លឿង។ «កង្កែប និងកណ្ដុរ» នាងបានគូរនៅក្នុងចំណិតរង្វង់ពណ៌ខៀវ។



«អ្ហ៎...!"» កូនចាប និងកូនពស់ភ្ញាក់ ពេលបានឃើញ លោកនាយកដំរីមកដល់ ។ ពេលនោះលោកនាយកដំរី បាន សួរទៅកូនចាប និងកូនពស់ថា «មើលទៅកូនៗដូចជាមិន សប្បាយចិត្តសោះ។ តើកូនៗមានរឿងអ្វីកើតឡើងមែនទេ?»។ កូនពស់ឆ្លើយទាំងអួលដើមកថា «ឪខ្ញុំ និងម៉ែចាបនិយាយ ថា យើងមិនអាចធ្វើជាមិត្តនឹងគ្នាបានទេ ពីព្រោះពួកយើង ខុសគ្នា»។ កូនចាបនិយាយថា «ពួកខ្ញុំចង់បង្ហាញប្រាប់ឪពុក ម្ដាយរបស់ពួកយើងថា ពួកយើងមានចំណុចដូចគ្នាច្រើនជាង ចំណុចខុសគ្នា ហើយពួកយើងអាចធ្វើជាមិត្តភក្តិនឹងគ្នាបាន។ ប៉ុន្តែ វាដូចជាមិនបានផលសោះ»។ លោកនាយកដំរីបាន ទាញមើលក្រដាសដែល កូនចាបបានគូរមួយសន្ទុះ ក៏សើច។ កូនចាប និងកូនពស់បានសម្លឹងមើលលោកនាយក។ តើមាន អ្វីគួរឱ្យអស់សំណើចមែនទេ? ទីបំផុត លោកនាយកក៏ជូត ទឹកភ្នែក ហើយនិយាយថា «កូនៗមើលមិនឃើញទេអី? កូនៗ ធ្វើបែបនេះមិនត្រូវទេ! ចាំខ្ញុំជួយពួកឯង!»។



លោកនាយកសាលាបានអង្គុយលើកៅអី រួចនិយាយថា «មើល៍កូនពស់! ឯងចូលចិត្តធ្វើអ្វីបំផុត?» ពស់និយាយថា «ចូលចិត្តលេងកម្សាន្ត និងជជែកគ្នា ជាពិសេសជាមួយចាប»។



លោកនាយកសួរទៅកូនចាបថា «ចុះឯងវិញ?»។ កូនចាប បានឆ្លើយតបមកវិញថា «ខ្ញុំក៏ចូលចិត្តនិយាយ និងលេងដែរ ជាពិសេសជាមួយពស់»។ «ល្អ! អ៊ីចឹងកូនទាំងពីរចូលចិត្ត របស់ដូចគ្នា»។ និយាយចប់លោកនាយកដំរីក៏គូររូបនៅផ្នែក ពណ៌បៃតង។ លោកនាយកសួរបន្តថា «សំណួរបន្ទាប់ តើ អ្វីដែលនាំឱ្យកូនទាំងពីរសប្បាយចិត្ត?»។ កូនពស់ឆ្លើយថា «នៅពេលដែលអ្នកគ្រូឱ្យខ្ញុំអង្គុយនៅជិតចាប» ហើយវាក៏សើច ស្របពេលជាមួយកូនចាបក៏ឆ្លើយទាំងទះដៃថា «ដូចគ្នា ដូចគ្នា លោកនាយក!»។



លោកនាយកស្រែកថា «អីយ៉ា! កូនទាំងពីរពិតជាមានចំណុច សប្បាយចិត្តដូចគ្នា។ ពណ៌បៃតង!»។ លោកនាយកដំរីសួរបន្ត ថា «ឥឡូវ តើអ្វីដែលធ្វើឱ្យកូនទាំងពីរមិនសប្បាយចិត្ត?»។ កូន ពស់ក៏ឆ្លើយទាំងមិនសប្បាយចិត្តថា «នៅពេលដែលឪរបស់ខ្ញុំ មិនឱ្យខ្ញុំលេងជាមួយចាប។» ហើយកូនចាបក៏ឆ្លើយទាំងទឹកមុខ មិនសើចដែរថា «នៅពេលម៉ែប្រាប់មិនឱ្យខ្ញុំលេងជាមួយពស់»។ លោកនាយកជ្រួញចិញ្ចើម ហើយនិយាយថា «មើលចុះ! កូន ទាំងពីរមិនសប្បាយចិត្តនូវរឿងដូចគ្នា មកពីឪពុកម្តាយរបស់កូន ៗហាមមិនឱ្យកូនៗលេងជាមួយគ្នា។ពណ៌បៃតងទៀត»។



«ជយោ!» កូនចាប និងកូនពស់ស្រែកហ៊ោ ហើយនាំគ្នានិយាយ
ថា «អរគុណ» ទៅលោកនាយក។ លោកនាយកនិយាយដោ
យមឺ◌ុងម៉ាត់ថា «អឺ មិនអីទេ! ហើយរឿងចុងក្រោយ គឺទៅប្រាប់
ឪពុកម្ដាយកូនៗឱ្យមកជួបលោកនាយកនៅព្រឹកស្អែក»។





និយាយឱ្យខ្លី! ការបែងចែក និងចាត់តាមក្រុមគឺជា ជំនាញសំខាន់នៅក្នុងគណិតវិទ្យា។ ដូច្នេះដើម្បីធ្វើវាបានល្អ មិត្តត្រូវសួរសំណួរជាក់លាក់ដូចជា ៖ ទី១ អ្វីជាភាពដូចគ្នា? អ្វីជាភាពខុសគ្នា? ទី២ តើចំណុចដូចគ្នានោះដូចគ្នារបៀបណា? តើចំណុចខុសគ្នានោះខុសគ្នារបៀបណា? ទី៣ តើចំណុចដែលដូចគ្នានោះអាចចាត់ចូលបានប៉ុន្មានរបៀប?





ឥឡូវនេះសាកល្បងគិតរកវិធីខុសៗគ្នាដែលប្អូនអាចបែងចែក និងចាត់ចូលក្រុមផ្សេងៗគ្នាបាន តាមរយៈតុក្កតាខាងលើ។ ប្អូនអាចបែងចែកដោយផ្អែកលើពណ៌តុក្កតាដូចជា តុក្កតាដែលមានពណ៌ខៀវដាក់ក្នុងមួយរង្វង់ ពណ៌លឿងដាក់ក្នុងមួយរង្វង់។ ចំណែកឯទំហំរបស់តុក្កតាវិញ តុក្កតាតូចដាក់ក្នុងមួយរង្វង់ តុក្កតាធំដាក់ក្នុងមួយរង្វង់ ។ ចំណុចមួយទៀតផ្អែកទៅលើចលនារបស់តុក្កតា ដូចជាសត្វដែលដើរ ខុសពីសត្វដែលហោះ។ ដូច្នេះ ចូរប្អូនសាកល្បងបែងចែក និងចាត់តាមក្រុមខុសៗគ្នា។

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*Same Same or Different*, Author: Roopa Pai. Illustrator: Rohit Kelkar. Published by StoryWeaver, © StoryWeaver. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by/4.0/
Contributing translators: Sodany Ouch